ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត
# ស្តីពីការបញ្ចប់ការស៊ើបសួររបស់តុលាការប្រឆាំងនឹង មាស មុត

នៅថ្ងៃនេះ **សហចៅក្រមស៊ើបអង្កេតអន្តរជាតិ** បានជូនដំណឹងទៅភាគីទាំងអស់នៃសំណុំរឿង ០០៣ ថា កិច្ចស៊ើបសួររបស់តុលាការនៅក្នុងសំណុំរឿង ០០៣ នេះ បានបិទបញ្ចប់ហើយ។ ភាគីពាក់ព័ន្ធនានាមានរយៈពេល ៣០ ថ្ងៃ ដើម្បីស្នើសុំការស៊ើបសួរបន្ថែមទៀត។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានចេញសេចក្តីសម្រេចផ្សេងមួយទៀតដែលកាត់បន្ថយវិសាលភាពនៃការស៊ើបសួររបស់តុលាការពាក់ព័ន្ធនឹង មាស មុត អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង។

សេចក្តីជូនដំណឹងថ្ងៃនេះ គឺជាការបិទបញ្ចប់កិច្ចស៊ើបសួររបស់តុលាការ ដែលធ្វើឡើងរយៈពេលជាង ៨ ឆ្នាំ លើ មាស មុត ទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងរវាងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ ការស៊ើបសួរប្រឆាំង មាស មុត បានបើកកិច្ចដំណើរការនីតិវិធី បន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ ដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់កាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។ ក្រោយមក វិសាលភាពនៃការស៊ើបសួរនេះ ត្រូវបានពង្រីកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់កាលពីថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៤។

កិច្ចស៊ើបសួរប្រឆាំងនឹងអតីតសហជនសង្ស័យមួយរូបទៀត ឈ្មោះ ស៊ូ ម៉េត ត្រូវបានបិទ បន្ទាប់ពីគាត់បានស្លាប់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ ២០១៥។

**សហចៅក្រមស៊ើបអង្កេតជាតិ** សូមកត់សម្គាល់ និងរំលឹកឡើងវិញ ថា សហចៅក្រមស៊ើបអង្កេតជាតិ និងអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk បានបិទ និងចេញសេចក្តីថ្លែងការណ៍ បិទកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១១។ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ តាំងពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ មកម្លេះ។

*ចំពោះព័ត៌មានបន្ថែមទៀត សូមទាក់ទង៖*

**លោកស្រី ហាយ៉ាត់ អាប៊ូ-សាឡេស**
មន្ត្រីព័ត៌មានសាធារណៈ
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ៩៣៦
សារអេឡិចត្រូនិក៖ abusaleh@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh